**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៣៤ ស.សរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីធ្វើវិសោធនកម្មច្បាប់ ស្តីពីការបង្ក្រាបអំពើពង្រត់លក់ដូរ និងធ្វើអាជីវកម្មលើមនុស្ស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីជូនដំណឹងលេខ១១៦៥ សជណ សរ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការយល់ព្រមឱ្យក្រសួងមហាផ្ទៃរៀបចំបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីពិនិត្យឡើងវិញច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ លក់ដូរ និងធ្វើអាជីវកម្មលើមនុស្ស
- យោងតាមសំណូមពរចាំបាច់

## <u>សំរេច</u>

<u>ប្រការ១</u>: ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីធ្វើវិសោធនកម្មច្បាប់ ស្តីពីការបង្ក្រាបអំពើពង្រត់លក់ដូរ និងធ្វើអាជីវកម្មលើមនុស្សដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ម៉ុល លីម** | ប្រធានក្រុមប្រឹក្សាអ្នកច្បាប់ក្រសួងមហាផ្ទៃ | **ប្រធាន** |
| ២-លោក | **ឃី ឈិត** | អនុប្រធាននាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ និងអនុគ្រោះទោសក្រសួងយុត្តិធម៌ | **អនុប្រធាន** |
| ៣-លោកស្រី | **សម មុន្នីកា** | អគ្គនាយករងកិច្ចការបច្ចេកទេសក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | **សមាជិក** |
| ៤-លោក | **ឌួច សាម៉ុន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសង្គមកិច្ចនិងយុវនីតិសម្បទា ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងនីតិសម្បទា | **សមាជិក** |
| ៥-ឧត្តមសេនីយ៍ត្រី | **ថោង លីម** | អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ | **សមាជិក** |



ឋ

៦- ឧត្តមសេនីយ៍ត្រី អ៊ុន សុគន្ធា ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន **សមាជិក**

៧-លោក ជុំ សៀកខួន ប្រធាននាយកដ្ឋានសុខុមាលភាពសង្គមនៃក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា **សមាជិក**

៨-លោក ម៉ៅ សុចត្តី អនុប្រធានភ្ជាប់រួមនាយកដ្ឋានសុខុមាលភាពកុមារនៃក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា **សមាជិក**

៩-លោក គឹម សុខណ្ណា ប្រធានការិយាល័យច្បាប់ឯកជន និងអន្តរក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **សមាជិក**

**ប្រការ២:** ក្រុមការងារអន្តរក្រសួងនេះមានភារកិច្ចដូចខាងក្រោម :

-ពិនិត្យឡើងវិញនូវភាពចន្លោះប្រហោងនៃច្បាប់ ស្តីពីការបង្ក្រាបអំពើពង្រត់ លក់ដូរនិងធ្វើអាជីវកម្មលើមនុស្ស ទាំងការកំណត់ទ័ណ្ឌកម្ម ការកំណត់ប្រភេទទោស ប្រភេទឧក្រិដ្ឋជន ព្រមទាំងបណ្តានីតិវិធីផ្សេងៗទៀត ដែលត្រូវស្ថិតនៅក្រោមច្បាប់នេះ ។

-ធ្វើកិច្ចពិភាក្សា ដោយសហការជាមួយអង្គការអន្តរជាតិដែលមានការពាក់ព័ន្ធ មន្ត្រីបច្ចេកទេសនៃក្រសួងកិច្ចការអន្តោប្រវេសន៍ ពហុវប្បធម៌ និងជនជាតិដើមរបស់អូស្ត្រាលី ដើម្បីផ្តួចផ្តើម និងកែសំរួលខ្លឹមសារសំរាប់បំពេញបន្ថែមទៅលើភាពចន្លោះប្រហោងនៃច្បាប់នេះ ហើយដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

**ប្រការ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០០៣

ឧបនាយករដ្ឋមន្ត្រី

ស ខេង

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីស ខេង
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន
- ដូចប្រការ១
- ឯកសារ-កាលប្បវត្តិ